# ជំងឺកញ្ជ្រឹល

## កញ្ជ្រឹលគឺជាជំងឺដ៏ធ្ងន់ធ្ងរមួយ



កញ្ជ្រឹល គឺជាជំងឺធ្ងន់ធ្ងរដែលបង្កឲ្យមាន. ្ម មកន្ទួលរមាស់ និងជំងឺគ្រុនក្តៅជំងឺកញ្ជ្រឹល គឺជាជំងឺឆង។

វាឆងរីករាលដាល នៅពេលដែលមនុស្សម្នាក់កើតជំងឺកញ្ជ្រឹលបញ្ចេញខ្យល់ដង្ហើម កកឬកណាស់។

អ្នកដែលមិនបានចាក់វ៉ាក់សាំងបង្ការ គឺអាចនឹងងាយឆងជំងឺកញ្ជ្រឹលជាងមនុស្សធម្មតា។

ជំងឺកញ្ជ្រឹលអាចនឹងមានគ្រោះថ្នាក់ ជាពិសេសសម្រាប់ទារក និងកុមារតូចៗ។ ករណីខ្លះ ជំងឺនេះអាចនឹងបង្កគ្រោះថ្នាក់ដល់អាយុជីវិតបាន។

## ការពារ គ្រួសារអ្នកពីជំងឺកញ្ជ្រឹល



វិធីដ៏លបំផុតក្នុងការការពារគ្រួសារអ្នកពីជំងឺកញ្ជ្រឹល គឺត្រូវចាក់វ៉ាក់សាំងបង្ការ។ គ្រូពេទ្យណែនាំថា កុមារទាំងអស់ត្រូវទទួលថ្នាំវ៉ាក់សាំង MMR។

ការទទួលថ្នាំវ៉ាក់សាំង MMR គឺមានសុវត្ថិភាព និងមានប្រសិទ្ធិភាពក្នុងការបង្ការជំងឺកញ្ជ្រឹល។ វាក៏ជួយ ការពារប្រឆាំងទៅនឹងជំងឺសាទ្បាទែន និងជំងឺស្វូចបានផងដែរ។

ការទទួលថ្នាំវ៉ាក់សាំង MMR គឺមានសុវត្ថិភាពជាងការបណោយខ្លួនឲ្យឆងជំងឺកញ្ជ្រឹល។

កុមារភាគច្រើនមិនទទួលរងផលអវិជ្ជមានពីការចាក់ថ្នាំវ៉ាក់សាំងនេះឡើយ។ ផលអវិជ្ជមានរបស់ថ្នាំដែលកើតមាន ជាធម្មតាគឺមានតិចតួចបំផុត និងមិនមានរយៈពេលវែងនោះឡើយ ដូចជា៖ គ្រុនក្តៅ កន្ទួលរមាស់ និងការឈឺខ្លួនប្រាណ។

## ថ្នាំវ៉ាក់សាំង MMR មិនបណាលឲ្យកើតមានជំងឺអូទីស៊ីមឡើយ

មិនមានការសិក្សាស្រាវជ្រាវណាមួយបងាញអំពីទំនាក់ទំនាងរវាងជំងឺអូទីស៊ីម និងថ្នាំវ៉ាក់សាំង MMR នោះឡើយ។ បញានេះត្រូវបាន ក្រុមវេជ្ជបណិត និងអ្នកវិទ្យាសាស្រទូទាំងពិភពលោក បានធើការសិក្សាស្រាវជ្រាវយ៉ាងប្រុងប្រយ័ត្នបំផុត។

អ្នកវិទ្យាសាស្រនានាកំពុងសិក្សាស្រាវជ្រាវទៅលើបុពហេតុដែលអាចនឹងធើឲ្យកុមារកើតមានជំងឺអូទីស៊ីម។អ្នកវិទ្យាសាស្រភាគច្រើន យល់ស្របថា សែនតំណពូជរបស់គ្រួសារអាចជាបុពហេតុនាំឲ្យបុគ្គលម្នាក់អាចនឹងកើតមានជំងឺអូទីស៊ីម។ អ្នកវិទ្យាសាស្រទាំងនោះក៏កំពុងសិក្សាផងដែរអំពីទំនាក់ទំនងរវាងជំងឺអូទីស៊ីម និងទីកន្លែងដែលមនុស្សរស់នៅ។

សូមសួរវេជ្ជបណិតរបស់អ្នក ប្រសិនបើអ្នកមានសំណួរអំពីជំងឺកញ្ជ្រឹល ឬថ្នាំវ៉ាក់សាំង MMR។

SACRAMENTO COUNTY

Sacramento County
Department of Health Services
Public Health Division

# តើអ្នកត្រូវធ្វើដូចមេច ប្រសិនបើអ្នកគិតថាអ្នកមានជំងឺកញ្ជ្រឹល

## រោគសញ្ញានៃជំងឺកញ្ជ្រឹល និងលក្ខណៈនៃការឆង

ជំងឺកញ្ជ្រឹលតែងចាប់ផ្តើមកើតមានតាមរយៈអាការគ្រុនក្តៅខ្លាំង កក ហៀរសំបោរ ភ្នែកឡើងក្រហម និងហូរទឹកភ្នែក។ បន្ទាប់ពីរយៈពេល 3-4 ថ្ងៃ កាយមក មានស្នាមរកន្ទួលរមាស់ចាប់ផ្តើមកើតមាននៅលើផ្ទៃមុខ និងរាលដាលទៅផ្នែកដទៃផ្សេងទៀតនៃរាងកាយ។

អ្នកអាចចមងជំងឺកញ្ជ្រឹលទៅមនុស្សផ្សេងទៀតបាននៅពេលអ្នកមានរោគសញ្ញាទាំងនេះ។ អ្នកនឹងចមងជំងឺនេះរហូតដល់ ស្នាមកន្ទួលរមាស់បាត់ទៅវិញ។

អ្នកអាចនឹងឆងជំងឺកញ្ជ្រឹលបាន ដោយគ្រាន់តែស្ថិតនៅក្នុងបន្ទប់មួយដែលមានអ្នកជំងឺកញ្ជ្រឹលធាប់ស្នាក់នៅ។

វីរុសកញ្ជ្រឹលស្ថិតនៅក្នុងខ្យល់រយៈពេលរហូតដល់ពីរម៉ោង បន្ទាប់ពីអ្នកជំងឺនោះចាកចេញពីបន្ទប់។

## សូមទូរសព្ទទៅកាន់វេជ្ជបណ្ឌិតរបស់អ្នកឬគ្លីនិកជាបន្ទាន់ ប្រសិនបើអ្នកពិនិត្យឃើញមានរោគសញ្ញាទាំងនេះ

វេជ្ជបណ្ឌិតរបស់អ្នកឬគ្លីនិក នឹងឲ្យអ្នកដឹងថា តើអ្នកចំបាច់ត្រូវចូលទៅកាន់គ្លីនិកដើម្បីធ្វើការពិនិត្យជំងឺដែរឬយ៉ាងណា។

ជំងឺកញ្ជ្រឹលគឺជាជំងឺងាយឆ្លង ហើយអ្នកអាចនឹងចមងជំងឺនេះទៅអ្នកដទៃទៀតនៅក្នុងបន្ទប់រង់ចាំ។ ចាំបាច់ត្រូវប្រាប់វេជ្ជបណ្ឌិតរបស់អ្នក ឬគ្លីនិកថា អ្នកមានរោគសញ្ញាជំងឺកញ្ជ្រឹល **មុនពេល**អ្នកទៅកាន់គ្លីនិក។ ពួកគេនឹងផ្តល់ការណែនាំដល់អ្នកអំពីអ្វីដែលអ្នកត្រូវធ្វើ ដើម្បីកុំឲ្យអ្នកចមងជំងឺកញ្ជ្រឹលនេះបាន។

## ត្រូវនៅផ្ទះ ប្រសិនបើអ្នកមានជំងឺកញ្ជ្រឹល

ចាំបាច់ មិនត្រូវចមងជំងឺកញ្ជ្រឹលទៅអ្នកដទៃឡើយ។

ត្រូវនៅផ្ទះ ប្រសិនបើអ្នកមានជំងឺកញ្ជ្រឹល។ មិនត្រូវទៅសាលារៀន កន្លែងធ្វើការ ទៅហាងលក់ទំនិញ ឬផ្ទះរបស់អ្នកដទៃផ្សេងទៀតឡើយ។

មិនត្រូវមានអ្នកមកសួរសុខទុក្ខនៅផ្ទះរបស់អ្នកឡើយ ប្រសិនបើអ្នក ឬកូនរបស់អ្នកមានអាការៈ គ្រុនក្តៅ ឬស្នាមកន្ទួលរមាស់។

Sacramento County
Department of Health Services
Public Health Division